ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

## តាមនាមប្រជារាស្ត្រខ្មែរ

សំណុំរឿងសភាព្រហ្មទណ្ឌ
លេខ : ៧១៩
ចុះថ្ងៃទី ១៤-១១-២០០៣
**សាលដីកា**
លេខ : ១២ "ជ"
ចុះថ្ងៃទី ២០-០២-២០០៨

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទី ២០-០២-២០០៨ ដោយមានសមាសភាពដូចខាងក្រោម :

<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ</u>

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

<u>តំណាងមហាអយ្យការ</u>

លោក [redacted] ជាព្រះរាជអាជ្ញា

<u>ក្រឡាបញ្ជី</u>

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៧១៩ ចុះថ្ងៃ ១៤-១១-២០០៣ រវាង :

១-ជនជាប់ចោទឈ្មោះ [redacted] មាន ភេទប្រុស អាយុ២៣ឆ្នាំ ទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន១នាក់ ។

-ចាប់ខ្លួនថ្ងៃទី ០៥-១២-២០០២ ឃុំខ្លួនថ្ងៃទី ១១-១២-២០០២ ។

-លោក [redacted] សារឿន មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

<u>ជាប់ចោទពីបទ</u> : ប្លន់ កាលពីថ្ងៃទី ១៩-១១-២០០២ តាមបញ្ញត្តិនៃមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-ជនរងគ្រោះឈ្មោះ [redacted] ឃីម ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ មុខរបររត់ម៉ូតូឌុប កើតនៅភូមិ [redacted] ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះជួល [redacted] ។

I-អំពីអង្គហេតុ

កាលពីថ្ងៃទី ២០-១១-២០០២ របស់ឈ្មោះ [redacted]យឹម បញ្ជាក់ថា កាលពីថ្ងៃទី ១៩-១១-២០០២ វេលាម៉ោង ១៩:៣០នាទី យប់ខ្លួនបានរត់ម៉ូតូឌុបមកត្រង់ចំណុចស្តុបពេទ្យចិន មានជនបីនាក់ហៅម៉ូតូជិះ ដោយនិយាយថ្លៃប៉ុន្មាន ខ្លួនទារ ៥០០០៛ ពួកវាឡើងជិះដោយឥតតថ្លៃ ដោយទៅរោងចក្រថ្មីតាមផ្លូវចោម ចៅមកដល់ដីវាលចាក់ថ្មីខាងកើតរោងចក្រស្បែកជើង បានអោយខ្លួនឌុបតាមផ្លូវលំ បានចំងាយប្រហែល ១០០ម ពីថ្នល់ធំស្រាប់តែពួកវាអោយម៉ូតូឈប់ ហើយអាម្នាក់ជិះពីក្រោយចុះពីលើម៉ូតូហើយវាយក្បាល ខ្លួនតែម្តង មិនដឹងថាពួកវាវាយក្បាលខ្លួននិងវត្ថុអ្វីទេ ពេលនោះខ្លួនសន្លប់ហើយពួកវាបានយកម៉ូតូជិះចេញ ទៅបាត់ទៅ ។

-បានឃើញ : សាលក្រមព្រហ្មទណ្ឌលេខ ៤៩ "ឈ" ចុះថ្ងៃទី ១៧-៧-២០០៣ របស់តុលាការក្រុងភ្នំពេញ បានសម្រេច សេចក្តីដូចខាងក្រោម :

១-ផ្តន្ទាទោសឈ្មោះ [redacted]មាន ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់៥(ប្រាំ) ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី ១១-១២-២០០២ តទៅ ពីបទ ប្លន់ ប្រព្រឹត្តនៅចំណុចរោងចក្រកាត់ដេរអន្តរជាតិ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ កាលពីថ្ងៃទី ១៩-១១-២០០២ បទល្មើសព្រហ្មទណ្ឌឱ្យ ផ្តន្ទាទោសតាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-ទុកសិទ្ធិឱ្យជនរងគ្រោះឈ្មោះ [redacted] យឹម ប្តឹងទារសំណងម៉ូតូនៅពេលក្រោយទៅតុលាការរដ្ឋប្បវេណី ។

៣-សាលក្រមនេះ ជំនុំជំរះប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ កំបាំងមុខជនរងគ្រោះ បើភាគីណាមិនសុខចិត្ត មានសិទ្ធិប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

<u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted]មាន (វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] (អវត្តមាន)

ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានរបាយការណ៍សង្ខេបរឿង

-ជនជាប់ចោទឈ្មោះ [redacted] មាន បានឆ្លើយថា នៅថ្ងៃទី ១៩-១១-២០០២ ខ្លួនពុំបានធ្វើ សកម្មភាពប្លន់ទ្រព្យសម្បត្តិគេទេ គឺខ្លួននៅផ្ទះជួល ខ្លួនជួលផ្ទះគេស្នាក់នៅដោយមានម្ចាស់ផ្ទះដឹងឮ។ ហើយនៅថ្ងៃទី ០១-១២-២០០២ វេលាម៉ោង៨យប់ ទើបខ្លួនចេញទៅធ្វើសកម្មភាពមានគ្នា៣នាក់ ឈ្មោះ ទុំ ឈ្មោះ តឿ ស្នាក់នៅផ្ទះជួលខាងលិចភូមឫស្សី សង្កាត់ស្ទឹងមានជ័យ ក្រុងភ្នំពេញ ឈ្មោះ តឿ ជាអ្នកឌុបខ្លួន ហើយខ្លួនជាអ្នកកាន់កាំភ្លើងក្ជង់ម្ចាស់ម៉ូតូឌុប ពេលនោះម្ចាស់ម៉ូតូប្រគល់ម៉ូតូឱ្យមក ខ្លួន ហើយខ្លួនបានជិះយកទៅអោយឈ្មោះ វុធ នៅភូមិទួលសង្កែ មិនស្គាល់លេខផ្ទះទេ ។ ពេលធ្វើ សកម្មភាពប្លន់នោះខ្លួនមិនបានបាញ់ទៅលើម្ចាស់ម៉ូតូឡើយ ។

សំណូមពរ : សូមក្រុមប្រឹក្សាលើកលែងចោទប្រកាន់ ដើម្បីអោយខ្លួនមានសេរីភាពវិញផង ។

**សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ :**

-ក្រោយពីបានពិនិត្យ លើសំណុំរឿងយល់ឃើញថា មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ លើ ជនជាប់ចោទ ។ តំណាងមហាអយ្យការសូមតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៩ "ឈ" ចុះថ្ងៃ ១៧-៧-២០០៣ របស់សាលាដំបូងក្រុងភ្នំពេញ ទុកជាបានការដដែល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ។
-ក្រោយពីបានស្តាប់អំនានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។
-ក្រោយពីបានពិនិត្យភស្តុតាងឯកសារនានា ។
-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

**<u>សាលាឧទ្ធរណ៍</u>**

**<u>យល់ឃើញថា</u>** :

-យល់ឃើញថា បណ្តឹងឧទ្ធរណ៍ចុះថ្ងៃ ០១-៩-២០០៣ របស់ជនជាប់ចោទ [redacted] មាន ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមបញ្ញត្តិមាត្រា ១៧៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចទទួលជំនុំជំរះបាន ។

លិខិតលេខ ៦៦៥ គម/០៣ ចុះថ្ងៃ ១-៧-២០០៣ របស់គណៈមេធាវី ចាត់មេធាវី [redacted] សារឿនការពារក្តីឱ្យជនជាប់ចោទមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-យល់ឃើញថា តុលាការថ្នាក់ក្រោម បានធ្វើការអង្កេតលើកយកភស្តុតាងមកសំអាងជូនសព្វគ្រប់អស់ហើយ ។ សាលាឧទ្ធរណ៍មិនលើកសំអាងហេតុដដែលមកបញ្ជាក់ជាថ្មីទៀតទេ ។

-យល់ឃើញថា សាលក្រមព្រហ្មទណ្ឌលេខ ៤៩ "ណ" ចុះថ្ងៃ ១៧-៧-២០០៣ មានលក្ខណៈត្រឹមត្រូវគួរតម្កល់ទុកជាបានការ ។

**<u>ហេតុដូច្នេះ</u>**

**<u>ឧនិច្ឆ័យសេចក្ត</u>**

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃ ០១-៩-២០០៣ របស់ជនជាប់ចោទ [redacted] មាន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយទាស់គតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៩ "ណ" ចុះថ្ងៃ ១៧-៧-២០០៣ របស់សាលាដំបូងក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣-សាលដីកានេះ ជំនុំជំរះថ្ងៃ ១៤-២-២០០៨ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈថ្ងៃ ២០-២-២០០៨

-បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

**<u>សេចក្តនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះ អោយបានសម្រេច ប្រសិនបើមានសំណូមពរ ត្រឹមត្រូវតាមច្បាប់</u>** ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| លេខា [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខា [redacted] |

---

បានយើញ
ប្រធានសាលាឧទ្ធរណ៍

បានផងផ្ទុំត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី២០ ខែ១២ ឆ្នាំ២០១៤...
ក្រឡាបញ្ជី

[redacted]